MARYKNOLL
Date ......

## ពាក្យឧទ្ទិស

ដើម្បីលើកតំកើងនូវវិស័យអក្សរសាស្ត្រខ្មែរ ក៏ដូចជាស្នាដៃរបស់កវីនិពន្ធជើងចាស់ដ៏ល្បីល្បាញ ដែលខំបញ្ចេញនូវទេពកោសល្យ ទឹកដៃនិពន្ធដ៏ប៉ិនប្រសព្វ សំរាប់ឱ្យកវីជំនាន់ក្រោយគ្រាន់បានយកជាទុនក្នុងការនិពន្ធរបស់ខ្លួន និងអស់លោកអ្នកនាងកញ្ញាដែលនិយមចូលចិត្តអានប្រលោមលោក ខ្ញុំបានខំស្រាវជ្រាវរករឿងដ៏ល្បីនេះ ដើម្បីរៀបចំបោះពុម្ពឡើងវិញនៅឆ្នាំ ២០០០ ។

សូមឧទ្ទិស ចំពោះលោក **មិត្ត សាខុន** ដែលជាអ្នកនិពន្ធ ប្រសិនបើលោកបានធ្វើមរណកាលទៅហើយ សូមវិញ្ញាណក្ខ័ន្ធលោកទៅកាន់សុគតិភព ហើយប្រសិនបើលោកនៅមានជីវិតនៅឡើយ សូមលោកព្រមទាំងគ្រួសារ បានជួបប្រទះនូវសេចក្តីសុខកុំបីឃ្លាងឃ្លាតឡើយ ។

**សុផល**

**មិត្ត សាខុន**

# អាថ៌កំបាំងបន្ទប់លេខ ១១

## ស៊ើបអង្កេត

**ទេពកោសល្យ ៦ប្រការរបស់លោកអធិការកិត្តិគុណ ÷**

១-មានបញ្ញាវៃឆ្លាតក្នុងការដោះស្រាយបញ្ហាស្មុគ្រស្មាញ
២-រូបសម្បត្តិជាទីគាប់ចិត្តនៃនារី
៣-សំដីពិរោះរណ្តំដូចកណ្តឹង និងផ្អែមត្រជាក់ដូចទឹកឃ្មុំ
៤-ចិត្តមុតដូចម្ជុល ក្លាហានអង់អាចដូចហនុមាន
៥-ប្រយុទ្ធមានល្បិចខ្ពស់ រញ្ជួយពិភពជនទុច្ចរិត
៦-ដំកើងករណីយកិច្ចធំជាងស្នេហា ។

មិត្តនិពន្ធខ្ញុំពុំមានចេតនាឱ្យប៉ះពាល់ដល់រូបបុគ្គលណាមួយទេ តែបើមានខ្លះក៏សូមមេត្តាកុំប្រកាន់ គឺជារឿងប្រឌិតរបស់អ្នកនិពន្ធខ្ញុំសុទ្ធសាធ ដោយប្រាថ្នាតែម៉្យាងគឺលើកតម្កើងទឹកដៃវិរបុរសខ្មែរ ផ្អែកស៊ើបអង្កេតតែប៉ុណ្ណោះ......

**សូមអរគុណ**



# ១

# ល្អាងកោះពស់

## ក្រុងព្រះសីហនុ......

ភ្លៀងធ្លាក់ខ្ទោកៗ តាំងពីរសៀលរហូតដល់ព្រលប់ក៏មិនទាន់ស្រាកទៀត បណ្ដាលឱ្យទីក្រុងទាំងមូលស្ងាត់ជ្រៀបរកតែមនុស្សម្នាក់ដើរក៏ពុំបានផង តែយូរៗយើងឃើញពន្លឺភ្លើងតាក់ស៊ីបញ្ចាំងទំលុះស្បៃព្រះភិរុណធ្លាច រួចបាត់ស្រមោលឈឹងតែម្ដង ។ ព្យុះស្គរតែដំណក់គ្រាប់ភ្លៀងធ្លាក់ប្រសៗ បោកដោយខ្យល់យ៉ាងខ្លាំងក្លា ក្រាលដណ្ដប់លើផ្លូវឡើងសសំពោង ។ ប្រហែលជាម៉ោង២២ហើយ យើងឃើញរថយន្តហ្ស៊ីបមួយល្ងូនតើមៗ ចូលទៅក្នុងបរិវេណស្នងការដ្ឋាន ដែលប្រតិស្ថានឆ្ងាយពីផ្សារប្រហែលពីររយម៉ែត្រប៉ុណ្ណោះ តាមផ្លូវឡើងទៅភ្នំពេញ ។ បុរសម្នាក់ពាក់មួកខ្មៅ បិទបាំងខ្លួនជិតដោយអាវភ្លៀងពណ៌ប្រផេះបានលោតចុះពីរថយន្ត ហើយដើរចូលទៅកាន់ការិយាល័យ ដែលមានភ្លើងបើកភ្លឺចិញ្ចែងជាធម្មតា ។ នៅក្នុងការិយាល័យមានមនុស្សពីរនាក់ពាក់មួក ពាក់អាវភ្លៀងដែរ ក្រោកទទួលអ្នកមក

ដល់ថ្មី ដោយធ្វើការកិច្ចដាក់គ្នាទៅវិញទៅមកយ៉ាងគួរសមបំផុត ។

បុរសមកដល់ថ្មីរលាស់ដៃឱ្យបាត់ស្រពន់ ដោយត្រូវត្រជាក់នឹងទឹកភ្លៀងអម្បាញមិញ រួចងាកមកកាន់មនុស្សទាំងពីរ បញ្ចេញវាចាយ៉ាងស្និទ្ធស្នាល ÷

-លោកស្នងការគាត់ត្រឡប់ពីផែមកវិញឬនៅ ?

-បាទ, មិនទាន់អញ្ជើញមកវិញនៅឡើយទេលោក ! តែលោកបានហៅទូរស័ព្ទមកអម្បាញមិញ ថាបើឃើញលោកអញ្ជើញមកសុំឱ្យលោកចាត់ការចុះទាន !

បុរសម្នាក់មាឧមាំ ភ្នែកធំៗ តបទៅកាន់បុរសមកដល់ថ្មីដោយគោរព ។

-លោកស្នងការគាត់ហៅពីណាមក ?

-បាទ ហៅពីកំពង់ផែមកទាន.......

បុរសមកដល់ថ្មី ដែលយើងពុំទាន់ស្គាល់ថាគេឈ្មោះអ្វីនៅឡើយនោះ ក៏ចាប់លើកបំពង់ទូរស័ព្ទមកកាន់រួចបង្វិលលេខបីបួនក្រិក ÷

-អាឡូ.......អាឡូ ពីស្នងការដ្ឋានព្រះនគរបាលជាតិ សុំអញ្ជើញលោកស្នងការមកកាន់ទូរស័ព្ទមួយភ្លែត ហើយប្រញាប់បំផុត ។

យើងឃើញបុរសនេះងក់ក្បាល ឈរសញ្ជឹងមួយសន្ទុះ ទើបញញឹមសួរទៀត ÷

-លោកស្នងការឬ ? បាទ....... បាទ........ ខ្ញុំបុរសពិសេស[១] ដែលលោកបានសន្យាឱ្យមកជួបនៅការិយាល័យ តើលោកបានប្រទះ

១-បុរសពិសេសបានសំដែងរួចមកហើយក្នុងរឿង "អាថ៌កំបាំងត្បូងពេជ្រនៅបរាំប៉ៃលិន"



អ្វីគួរឱ្យសង្ស័យខ្លះទេ ?

យើងពុំបានឮសំលេងលោកស្នងការឆ្លើយតបទេ តែយើងសង្កេតឃើញមុខបុរសពិសេសជួនស្លុត ជួនជ្រួញចិញ្ចើម ហើយអស់មួយសន្ទុះធំទើបតបវិញ ÷

-ខ្ញុំបានបង្អប់ខ្លួនអស់ជិតកន្លះយប់ហើយ តែពុំបានលទ្ធផលអ្វីសោះ នាំតែរងាឥតប្រយោជន៍ ប៉ុន្តែមិនសូវធុញទ្រាន់ទេ ព្រោះជាករណីយកិច្ចរបស់ក្រុមយើង ដែលត្រូវតែបំពេញដោយខានមិនបាន ។ លោកបានផ្តាំឱ្យខ្ញុំចាត់ការនោះតទៅទៀតមែនទេ ?

បុរសពិសេសញញឹមងក់ក្បាលតែម្នាក់ឯង ជាមួយបំពង់ទូរស័ព្ទរួចក៏ដាក់មកវិញ ហើយងាកទៅកាន់សហការីទាំងពីរដែលអង្គុយចាំស្តាប់ក្បែរនោះ....... ÷

-បងព្រិល ! បងឯងត្រូវទៅភូមិនេសាទជាប្រញាប់ ដើម្បីឃ្លាំចាំមើលចលនាពួកវានោះ ហើយជាពិសេសបងឯងត្រូវប្រយ័ត្នបំផុតក្នុងពេលជិតភ្លឺហ្នឹង !

បុរសឈ្មោះព្រិល មាឧមាំ ដែលជាភ្នាក់ងារសម្ងាត់ដ៏ក្លាហានប្រចាំស្នងការដ្ឋានក្រុង ក្រោកឈរឡើងយ៉ាងរហ័សហាក់ដូចពេញចិត្តចំពោះមុខការ ដែលបុរសពិសេសប្រគល់ឱ្យបំពេញនេះណាស់ ទើបគាត់សួរតប ÷

-ក្រៅពីនេះ តើមានរឿងអ្វីទៀតទេលោក ?

-មាន ! ទូកនេសាទដែលចតនៅទីនោះទាំងប៉ុន្មាន ត្រូវពិនិត្យមើលឱ្យមែនទែន ក្រែងវាលួចចេញទៅរួចដោយនាំទាំងរបស់ដែល

យើងកំពុងតាមនេះ ទៅលាក់នៅទីកន្លែងផ្សេងទៀត មុខតែមានការលំបាកដល់ពួកយើងច្រើនទៀតមិនខាន ។

ព្រឹលភ្នាក់ងារទីមួយឱនក្បាលដើរចេញទៅក្រៅយ៉ាងក្លាហាន ពុំមានរួញរាចំពោះរន្ទះ តំណក់ភ្លៀង និងធាតុរងាបន្តិចឡើយ នេះហើយជាភស្តុតាងនៃអ្នកធ្វើការបំរើជាតិ ។ ព្រឹលចេញផុតទៅ ទើបបុរសពិសេសងាកមកកាន់ជនទីពីរទៀត ÷

-ភីនឯងធ្លាប់ស្គាល់ម្ចាស់បារក្លូឡាបសដែរឬទេ ?

ភីនជាភ្នាក់ងារទីពីរ បង្ហុយផ្សែងបារីពីមាត់តបថា ÷

-បាទ ! ធ្លាប់ស្គាល់ដែរ តែពុំសូវជាជិតដិតប៉ុន្មានទេ ព្រោះខ្ញុំបាទមិនសូវចេញចូលបារនោះញឹកញាប់.......

បុរសពិសេសទាញរូបថតមួយសន្លឹក មកដាក់ពីមុខភ្នាក់ងារភីន ÷

-នេះជារូបប្តីប្រពន្ធម្ចាស់បារនោះមែនទេភីន ?

សែហ្វភីនឈ្ងោកពិនិត្យរូបថតបន្តិច ទើបងើបក្បាលតបវិញ ÷

-បាទ ! ហ្នឹងហើយ.....តែប្រពន្ធដូចមិនមែនហ្នឹងទេលោក......

-ខ្ញុំបាទស៊ើបដឹងរួចហើយ រូបស្រីនេះជាប្រពន្ធដើមរបស់គាត់ ដែលសព្វថ្ងៃបើកហាងលក់ទំនិញយ៉ាងធំមួយ នៅមហាវិថីព្រះបាទមុនីវង្សភ្នំពេញ ហើយស្រីម្នាក់ដែលមកធ្វើជាម្ចាស់បារជាមួយគាត់នេះជាប្រពន្ធចុង ឬក៏ជាសាហាយរបស់គាត់ប៉ុណ្ណោះ ។ គាត់នោះឈ្មោះមុយជាអ្នកជំនួញមានឈ្មោះម្នាក់នៅក្នុងស្រុកខ្មែរ តែដល់ក្រោយមកត្រូវក្រសួងមានសមត្ថកិច្ចចាប់បាន ពីបទរត់គយអីវ៉ាន់ទៅបរទេស ហើយក៏ត្រូវរាជការពិន័យជាច្រើន ។ តាំងពីពេលនោះមកក៏បាត់មុខ



ពីភ្នំពេញតែម្តង ស្រាប់តែឥឡូវក៏ឃើញគាត់ធ្វើជាថៅកែបារនៅឯណោះវិញ ហើយមានអ្នកឱ្យការខ្លះថា គាត់កំពុងរៀបចំផែនការរត់គយធំៗណាស់ ប៉ុន្តែមិនទាន់ច្បាស់ ដូច្នេះយើងត្រូវប្រយ័ត្នល្បើបគាត់ហ្នឹងបន្តិច ព្រោះគាត់ហ្នឹងធ្លាប់មានរឿងរួចម្តងហើយ ។

ភីនងើបសម្លឹងមុខបុរសពិសេសរួចតប ÷

-ខ្ញុំឮគេថា គាត់នេះមានកាណូតឈ្នួលរត់ពីក្រុងយើងនេះ ទៅកោះកុងដល់ទៅពីរឯណោះ តែខ្ញុំមិនបានជាចាប់ភ្លឹកចំពោះបញ្ហានេះ.

-យើងត្រូវប្រយ័ត្នបន្តិច ចំពោះមនុស្សដែលមានស្នាមរួចមកហើយភីន ! តើកាណូតគាត់នោះលេខប៉ុន្មានខ្លះ ?

-ខ្ញុំមិនទាន់ស្គាល់ដែរ តែស្អែកនេះខ្ញុំនឹងជូនមកលោកឱ្យបានស្គាល់ភ្លាម....... ។

-ប៉ុន្តែភីនឯងត្រូវបំពេញបេសកកម្មធំមួយ ដែលគ្មានអ្នកណាក្រៅអាចធ្វើបាន ។

-សូមលោកចេញបញ្ជាមកចុះ ទោះបីជាធំប៉ុនភ្នំព្រះសុមេរុក៏ខ្ញុំមិនរួញរាដែរ ធ្វើជ្រូកហើយមិនរាទឹកក្តៅទេទាន......

បុរសពិសេសលើកដៃទះស្មាភ្នាក់ងារសំណប់មួយដៃ ហើយបន្លឺសំលេងឡើងថា ÷

-ត្រូវភីនឯង ធ្វើការទាក់ទងជាមួយប្រពន្ធចុងថៅកែបារនេះឱ្យបានក្នុងពេលឆាប់ៗ ទោះបីត្រូវកាន់នាទីអ្វីក៏ដោយ ជាសាហាយស្រីនោះក៏បាន ឬជាតួលីក្នុងបារនោះក៏បាន ហើយបើត្រូវការចំណាយប៉ុន្មានក៏តាមចិត្តចុះ រួចពីនោះមកបើកិច្ចការទាក់ទងបានសម្រេចហើយ ច

ចាំខ្ញុំប្រាប់ការធំៗជាក្រោយ ។

សែហ្សភីនបើកភ្នែកធំៗ ÷

-ខ្ញុំមិនហ៊ានលួចប្រពន្ធគេទេលោក.......

-បើសិនជាកាលៈទេសៈបង្គាប់ហើយ ភីនឯងត្រូវតែហ៊ាន ព្រោះករណីយកិច្ចយើងវាធំជាងអ្វីទាំងអស់ ហើយបើការប៉ុណ្ណោះភីនឯងធ្វើមិនកើតដែរ ថ្ងៃក្រោយថ្ងៃមុខភីនឯងនឹងក្លាយទៅជាអន់បំផុតនៅក្នុងក្រសួងយើង ។

សែហ្សភីនសញ្ជឹងគិតធ្វើភ្នែកម៉ក់ៗ ÷

-ខ្ញុំប្រថុយតាមលោកបញ្ជាម្តងចុះ ប៉ុន្តែត្រូវលោកទទួលឡើងរកាដែកជំនួសខ្ញុំផងបានទេទាន ?

បុរសពិសេសសើច ÷

-បាន ! ខ្ញុំព្រមឡើងជំនួស ប៉ុន្តែភីនឯងតោងដឹងថា នាងនោះមិនមែនជាប្រពន្ធពេញច្បាប់របស់ថៅកែមុយនោះទេណា៎ !

-អត់ទោស នាងនោះឈ្មោះអីលោក ?

-នាងឈ្មោះថាវីរ៍ ល្អផ្តាច់គេក្នុងស្រុកយើងនេះ អ្នកណាក៏គេចង់បាននាងធ្វើជាសាហាយដែរ ប៉ុន្តែវាគ្មានសំណាង ។ ប្រហែលជាសំណាងភីនឯងខ្ពស់ផុតគេហើយ ទើបវាសនាតម្រូវឱ្យភីនឯងទៅបំពេញកិច្ចការនេះ......ហាៗ......

ភ្នាក់ងារសម្ងាត់ទាំងពីរសើច មើលមុខគ្នាកញ្ជៀកដូចទឹកធ្លាក់ពីមាត់ក្អម បន្ទរជាមួយស្នូរទឹកភ្លៀងដែលបានលាន់ប្រសៗ មកលើកញ្ចក់ទ្វារបង្អួច ។



**ព្រលឹម**ឡើង មេឃស្រឡះល្អេវ ផ្ទៃគង្គាផ្លូញអង្គាញ់ៗតាមជំនោរពេលព្រហាម ។ នាវាបរទេសធំដូចភ្នំៗ បណ្តែតខ្លួននៅកំពង់ផែហើយចលនានៃការដាក់ទំនិញចុះ និងជញ្ជូនទំនិញឡើងក៏ចាប់ផ្តើមឡើងយ៉ាងសកម្មនៅក្រោមស្នូរគ្រឿងយន្តផ្សេងៗ និងសម្រែកកម្មករ។ នាវាមួយដែលយើងយកចិត្តទុកដាក់បំផុតនោះ ជារបស់សាសន៍ដាណឺម៉ាកដែលធំជាងគេ ហើយផ្ទុកអីវ៉ាន់ច្រើនជាងគេដែរ ប៉ុន្តែយើងពុំបានដឹងថាផ្ទុកអីវ៉ាន់អ្វីខ្លះទេ ។ ខណៈនោះ យើងឃើញរថយន្តម៉ាកតូយោតារបស់ថៅកែមុយ ដែលកាន់ចង្កូតដោយប្រពន្ធក្មេងរបស់គាត់ឈ្មោះថាវីរ៍នោះឯង ។ គួរឱ្យឆ្ងល់ណាស់ ! ថៅកែមុយជាម្ចាស់រង្គសាលសោះ ហេតុម្តេចក៏គាត់មកបញ្ចេញរូបរាល់ពេលវេលា នៅលើផែកុំពាល់នេះ ?

ថាវីរ៍ នារីក្មេងស្អាត ពាក់អាវក្រហម ស្លៀកខោពណ៌ខៀវ វ៉ែនតាខ្មៅ វិតតែលើកសាច់មុខនាងដែលគេដាក់ថា ជាភក្ត្រព្រះចន្ទ្រហើយនោះ ឱ្យកាន់តែស្រស់សោភ័ណឡើងទៀត ។ ដំណើរល្វតល្វន់ដូចកិន្នរបវរកញ្ញាស្ថានកៃលាស ដឹកដៃប្តីចាស់អាយុបងនាងជិតពាក់កណ្តាលឡើងតាមជណ្តើរទៅលើនាវា ។ ឈានទើបតែបានពីរកាំបុរសមាឌធំៗពីរនាក់ ដែលយើងឃើញភ្លាមអាចស្គាល់បានភ្លាមថាជាកម្មករលីសែងធ្វើការនៅទីនោះ ក៏ស្ទុះចូលមកជិត ហើយបន្ទន់ខ្លួនគោរពយ៉ាងសមគួរ ដូចនាយចៅហ្វាយនិងខ្ញុំបំរើ ។

នារីងាកមុខមើលឆ្វេងស្តាំបន្តិច ទើបបើកចំពុះសេកបញ្ចេញស្នូរសៀងពិរោះរណ្តំឡើងថា ÷

-ពូខ៊ី ! ពូខិត ! ពួកយើងមកប៉ុន្មាននាក់ថ្ងៃណេះ ?

ខ៊ីនិងខិត ជាឈ្មោះកម្មករពីរនាក់ដែលបានប្រាកដខ្លួនមកគោរព ចៅហ្វាយអម្បាញមិញ ។

នាយខ៊ីងាកមើលនាយអាយបន្តិច ទើបតបដោយគោរព ÷

-បាទ ! មកទាំងអស់គ្នាអ្នកស្រី តែពួកយើងត្រូវលាក់មុខខ្លះ...

ថៅកែមុយដកខ្សៀពីមាត់ គោះបង្កាន់ដៃប៉ូកៗ ÷

-មានមនុស្សដើរមកហើយ នៅឱ្យស្ងៀមសិន !

បុរសម្នាក់ស្លៀកពាក់ខៀវ និងពាក់កាតិបខៀវដែរនោះ បានបោះជំហានហួសទៅដោយពុំមានចាប់ភ្លឹក ចំពោះការសន្ទនារបស់គេនេះឡើយ ។

ថៅកែមុយបន្ត ÷

-ត្រូវប្រយ័ត្នបន្តិច ការនេះតែបែកកាលណា មុខជាជីវិតពួកយើងលែងប្រែដូចទឹកសមុទ្រទៀតហើយ !

ថាវីញាក់មុខដាក់ប្ដីសម្លាញ់បន្តិច ទើបបន្ថែម ÷

-ហើយបើបានសម្រេចវិញ ពួកយើងក៏នឹងមានតម្លៃលើសពីពេជ្រទាំងគ្រាប់ទៅទៀត ដូច្នេះត្រូវគិតថាជីវិតយើងមានតម្លៃណាស់ បើកាលណាយើងធ្វើការនេះឱ្យបានលទ្ធផលល្អជូនចៅហ្វាយយើង ។

នាយខ៊ីនិងនាយខិត ញាក់មុខទទួលពាក្យនារីលេបភ្លឹក ហើយនាយខិតបន្ត ÷

-ខ្ញុំប្រុងជើងអុក ដើម្បីធ្វើការនេះឱ្យបានប្រសើរជូនចៅហ្វាយមិនឱ្យទាស់ចិត្តទេ តែពួកខ្ញុំត្រូវការសោហ៊ុយខ្លះ..... បាទ.....



ថាវីបើកកាបូបទាញក្រដាស់ប្រាក់មួយរយៗមួយបាច់ ហុចមកឱ្យនាយខិត ក្នុងឱកាសដែលកម្មករអាវខៀវអម្បាញមិញដើរត្រឡប់មកវិញ ទើបនាងនិយាយបំភ័ន្តថា ÷

-ឯងយកលុយនេះទៅទិញស្រា និងម្ហូបអាហារខ្លះយកទៅបារមុនទៅ ខ្ញុំទៅតាមក្រោយឥឡូវហើយ ។

កម្មករអាវខៀវនៅឈរត្រង់សសរជង់គោមជិតនោះ ហួចខ្សៀវៗមើលទៅសមុទ្រហាក់ដូចជាកំពុងតែកំសត់ខ្លួនតាមទឹករលក។ ថៅកែមុយញាក់មុខឱ្យនាយខិតនិងខ៊ី រួចពីរនាក់ប្ដីប្រពន្ធ ក៏ឡើងទៅក្នុងកចាល់បាត់ក្នុងពេលនោះទៅ ។ ឯនាយខ៊ីនិងខិតក៏ដើរមកជិតកម្មករអាវខៀវដែលកំពុងឈរហួច ហើយសម្លឹងមុខកម្មករនោះបន្តិច ទើបវានាំគ្នាដើរហួសទៅ ។

នាយខ៊ីសួរក្លើថា ÷

-ហ្អែងធ្លាប់ស្គាល់អាម្នាក់ហ្នឹងទេ ?

-បែបវាទើបតែចូលថ្មីទេអា......... ។

នាយខ៊ីកេះក្លើឱ្យឈប់ ÷

-អញសង្ស័យក្រែងវាជាអ្នកតាមដានលោកថៅកែនិងអ្នកស្រី.....។

-បើសង្ស័យអញ្ចឹងសំឡេះវាចោលឱ្យហើយទៅ កុំទុកឱ្យនៅយូរទៀតអាថ្លើម(នាយខិតខាំមាត់តបទាំងលួចសម្លឹងទៅកម្មករនោះផង)

-កុំអាលចាត់ការទាំងថ្ងៃក្រឡែតអីចឹងអា ! ចាំយប់ហ្នឹងចាប់បោះវាទៅឱ្យឆ្លាមស៊ីតែម្ដងទៅ វាស្រេចទៅហើយ បើគេរកភ័ស្តុតាងក៏មិនឃើញដែរ ! ។

-មែនអា ! យប់ហ្នឹងគេទម្លាក់អីវ៉ាន់យប់ ក៏ដូចជាបើកឱកាសឱ្យយើងបានបញ្ជូនវាទៅស្ថានបាដាលអីចឹងដែរ !

នាយខ្ទិតបដោយលួចចោលភ្នែកទៅមើលកម្មករនោះ ដែលឈរធ្វើព្រងើយ ពុំចាប់ភ្ញីកចំពោះគ្រោះថ្នាក់ ដែលនឹងធ្លាក់មកដល់ខ្លួនឡើយ ។

ក្នុងពេលនាយខ្ទីនិងនាយខ្ទិតនិយាយគ្នានេះ មានមនុស្សម្នាក់ទៀតដើរមកឈរស្តាប់ពីក្រោយខ្នងវាបន្តិច រួចក៏ដើរហួសទៅដោយពុំបានធ្វើឱ្យនាយទាំងពីរចាប់ភ្ញីកបន្តិចឡើយ ។ ហើយក៏រត់ឡើងតាមជណ្តើរទៅក្នុងកប៉ាល់បាត់ភ្លាមទៅ ។

ប្រហែលជាងពីរម៉ោង ទើបយើងឃើញចៅកែមុយនិងភរិយាដើរចុះមកវិញ ហើយនាយទាំងពីរទៅទទួលដល់មាត់ជណ្តើរដោយចិត្តរីករាយ ។

ថាវរីប្រាប់យ៉ាងរហ័សមកថា ÷

-បានការខ្លះដែរ តែយប់នេះយើងត្រូវទៅជួបជុំគ្នានៅភូមិនេសាទដើម្បីឆ្លងទៅកាន់កន្លែងពិសេសរបស់យើង ស្តាប់បានឬនៅ ?

នាយខ្ទិតញាក់ស្មាបន្តិច ÷

-ខ្ញុំសូមបាត់ការអាម្នាក់នោះឱ្យហើយសិនអ្នកស្រី....... ។

នាយនោះប្ចូញមាត់ទៅរកកម្មករអាវខៀវ ដែលឈរហួចនៅក្បែរសសរដងគោមអម្បាញមិញ ស្រាប់តែគេនោះធ្វើភ្នែកស្ញីនិយាយលែងចេញ ព្រោះកម្មករនោះបាត់ស្រមោលពីកន្លែងឈរ ដូចចេះបំបាំងខ្លួន បណ្តាលឱ្យចៅហ្វាយនិងអ្នកបំរើខ្វល់ខ្វាយយ៉ាងខ្លាំង ។



ចៅកែមុយងាកឆ្វេងស្តាំ និយាយថា ÷

-ច្បាស់ជាវាស្តាប់យើងបានខ្លះមិនខានទេ ត្រូវឯងពីរនាក់រកវាឱ្យឃើញ ហើយបញ្ជូនវាទៅស្រុកវិញចុះ ។

ពោលដូច្នោះហើយ ចៅកែនិងប្រពន្ធក៏ដឹកដៃគ្នាចូលឡាន ហើយក៏បញ្ឆេះម៉ាស៊ីនបាកចេញពីទីនោះភ្លាម ។

កិច្ចការអាថ៌កំបាំងរបស់ចៅកែមុយ និងថាវរីម្ចាស់រង្គសាលក្លឹបស ធ្វើឱ្យយើងគិតមិនលេចសោះ មិនដឹងថាតើអ្នកទាំងនោះមុជទៅច្រកណា ? យើងចាំមើលបន្តិចទៀត.......

យប់នេះស្ងប់ខ្យល់ជាងសព្វមួយដង នៅភូមិនេសាទគេបិទទ្វារចូលនិទ្រាលង់លក់ស្កាត់ឈឹង....... អំពិលអំពែកញែកខ្លួនតាមចុងស្រល់បញ្ចេញពន្លឺភ្លែតទៅលិចភ្លៀវទៅកើត ។ ម៉ាស៊ីនកាណូតមួយរោទិ៍ទ្រហឹងឡើង ហើយក៏ងាកចេញពីកំពង់កាត់ឆ្ពោះទៅកាន់កោះពស់ដែលបណ្តែតអន្ទាយនៅចំពីមុខក្រុងព្រះសីហនុ ជាកោះមួយដែលយើងឈានជើងទៅដល់ក្រុងនេះភ្លាម យើងត្រូវចាប់ភ្នែកទៅលើកោះនេះមុនគេបង្អស់ ។ ដោយមិនចង់ឱ្យមានការជួបប្រទះជាមួយកាណូតរាជការយើង កាណូតចៅកែមុយត្រូវតែវាងចេញទៅឱ្យឆ្ងាយបន្តិច រួចទើបបត់ក្បាលចូលទៅកាន់ទីកោះពីទិសខាងលិចវិញ ។

កាណូតចូលចតនៅកំពង់សម្ងាត់ភ្លាម ពន្លឺភ្លើងពិលមួយក៏បញ្ចាំងឆ្វាចពីចង្កេះកោះមក ហើយនាយខ្ទិតក៏ហក់ទៅលើថ្មរួចចុចពិលបញ្ចាំងតបវិញ តាមសញ្ញាដែលគេធ្លាប់ប្រើទាក់ទងគ្នាជាអចិន្ត្រៃយ៍ ។

លុះចងកាណូតបានស្រួលបួលហើយ ទើបយើងឃើញនាងថាវរី

ថៅកែមុយ នាយខ្វី និងបុរសបីនាក់ទៀតសុទ្ធសឹងជាដៃជើងរបស់គេ ហក់ប្រសាចឡើងទៅដែរ ។ នាយខ្វិតបានបញ្ចាំងពិលដើរនាំមុខ រហូតទៅដល់មាត់រូងមួយ ទើបមានសម្លេងមនុស្សប្រុសស្រែកគ្រលៗ មកថា ÷

-ពួកលោកថៅកែឬ ?

-ហ្នឹងហើយ ! ក្រុមក្លូឡាប-ស ពីត្រើយម្ខាង !

-សូមអញ្ជើញក្រុមក្លូឡាបសចូលក្នុងរូងជាប្រញាប់ ព្រោះមានមនុស្សពីរនាក់មកចាំនៅខាងក្នុងយូរហើយ ។

ក្រុមក្លូឡាបសដែលមានថៅកែមុយ និងថាវរីនាំមុខ បានដើរចូលទៅក្នុងរូងកោះយ៉ាងស្ងាត់ស្ងៀម ដោយមានពន្លឺពិលពីរបីវាសវាត់បង្ហាញផ្លូវផង ។ រូងនេះបើមិនដែលស្គាល់ ចូលទៅហើយច្បាស់ជារកច្រកចេញវិញពុំបានឡើយ ព្រោះមានបន្ទះថ្មខណ្ឌជាបន្ទប់ខ្លះ និងផ្លូវខ្វាត់ខ្វែងពិបាកចំណាំបំផុត ។

ក្រុមក្លូឡាបសបានមកដល់ល្អាងមួយមូលក្លំ តែមានសណ្ឋានដូចជាបាតខ្ទះ ហើយមានពន្លឺភ្លើងថ្មស្អុយចាំងពីគ្រប់កន្លៀតថ្មយ៉ាងច្បាស់ទែងដូចថ្ងៃ ។ នៅទីនោះមានតុ កៅអី និងគ្រឿងប្រដាប់សម្រាប់ប្រើប្រាស់ជាច្រើនទៀត ហើយមានហីបឈើបន្តុបលើគ្នាពីរបីជួរដែលគ្មានអ្នកណាដឹងថាមានអ្វីនៅក្នុងនោះឡើយ ។

ឯមនុស្សដែលសម្រាប់ការពារល្អាងនេះ ក៏ពុំឃើញស្រមោលដល់ម្នាក់ឡើយ សូម្បីតែជននាំផ្លូវអម្បាញមិញ ក៏មិនដឹងជាភៀសខ្លួនទៅទីណាបាត់ភ្លាមទៅដែរ ។

HUN SEN LIBRARY R.U.P.P.



ក្នុងពេលក្រុមក្លូឡាបសអង្គុយ[illegible]ហើយ មនុស្សពីរនាក់មានឱខ្ពស់ៗដូចគ្នា សម្លៀកបំពាក់ហឹហាតាមបែបអឺរុប តែសាច់ឈាមបែបដូចជាចិនបង្កិចខ្មែរបន្តិច ។ ជនទាំងពីរដើរមកចាប់ដៃថៅកែនិងអ្នកស្រីថាវរី ដើម្បីថ្លែងសេចក្តីគួរសម ទើបថាវរីបញ្ជាក់ប្រាប់ប្តីថា ÷

-លោកនេះឈ្មោះស៊ីបេ ជាអ្នកជំនួញព្រៃសំពត់ធំបំផុតនៅហុងកុង ហើយម្នាក់នេះឈ្មោះ ហ៊ូឡាង ជាថៅកែមាសលេខមួយនៅក្រុងហុងកុងដែរ ។

ថៅកែមុយចាប់ដៃអ្នកជំនួញធំៗទាំងពីរ រលាក់ស្មើរដាច់ក្លៀក ហើយនិយាយថា ÷

-ខ្ញុំមានចិត្តរីករាយណាស់ ដោយបានលោកទទួលស្គាល់ក្នុងពេលនេះ ហើយជាពិសេសខ្ញុំមិនភ្លេចគុណលោកទេ ដែលបានបញ្ជូនថាវរីមកឱ្យធ្វើជាប្រពន្ធខ្ញុំនេះ ។ អាស្រ័យដោយនាងចេះច្រើនភាសា ទើបពួកខ្ញុំអាចធ្វើការទាក់ទងជាមួយអ្នកជំនួញបរទេសបានងាយ គ្រប់ទីកន្លែង ។

គេញញឹមដាក់គ្នា ទើបថាវរីនិយាយបន្តពីប្តី ÷

-កាលខ្ញុំនៅស្រុកសៀម ខ្ញុំបានរៀនភាសាអន្តរជាតិចេះជាច្រើន ហើយដល់ខ្ញុំទៅនៅហុងកុង ក៏រឹតតែជំនាញថែមទៀត ចំណែកឯភាសាខ្មែរខ្ញុំជាកូនកាត់ខ្មែរស្រាប់ ម្ល៉ោះហើយខ្ញុំអាចនិយាយបានស្ទាត់តែក្នុងរវាងមួយឆ្នាំប៉ុណ្ណោះ ។

ថៅកែហុងកុងទាំងពីរ លើកដៃទះស្មានរីស្រាលៗព្រមគ្នា ទើបហ៊ូឡាងបន្ទឺសម្លេងមួយៗថា ÷

-ខ្ញុំពីរនាក់បន់ឱ្យតែក្រុមក្លូឡាបសរកស៊ីមានបាន ឆាប់ទាន់ចិត្តផ
ដើម្បីកុំឱ្យពួកខ្ញុំពិបាកធ្វើដំណើរពីហុងកុងមកជួយណែនាំទៀត ព្រោ
ខាតពេលខ្ញុំរកស៊ីសមៀមណាស់ ។

ថៅកែស៊ីបេបញ្ជាក់គាត់ភ្លាម ÷

-ដើម្បីកុំឱ្យយឺតការ យើងត្រូវនិយាយពីសាច់ការយើងវិញម្តង
ម៉េចទៅលោកថៅកែធំនៅភ្នំពេញ មានឱ្យដំណឹងអ្វីខ្លះមកទេ ពីរឿ
មាសនិងសំពត់ព្រៃគ្រប់មុខនោះ ?

ថាវីងាកមើលមុខប្ដីបន្តិច និងសហការីដែលមកជាមួយ ដោយ
ចេញបញ្ហាថា ÷

-នាំគ្នាថយទៅក្រៅសិនទៅ ព្រោះយើងត្រូវការជំនុំបញ្ហានេះ
ដោយសម្ងាត់បំផុត !

នាយខិតនាយខឺ និងអ្នកលេងបីនាក់ទៀត ក៏ដកខ្លួនចេញទៅក្រៅ
អស់ជាបន្ទាន់ ទើបថាវីងាកមកឆ្លើយ ចំពោះសំនួរថៅកែហុងកុង
វិញ ÷

-លោកថៅកែធំនៅភ្នំពេញ ពុំបានបញ្ជាក់សព្វគ្រប់ជាមួយពួកខ្ញុំទេ
គាត់គ្រាន់តែមានពាក្យផ្ដាំបន្តិចបន្តួច និងសំបុត្រមួយប៉ុណ្ណោះមកជូន
ថៅកែ តែខ្ញុំពុំបានដឹងថាសំបុត្រនេះគាត់និយាយពីបញ្ហាអ្វីនៅឡើយ
ទេ...... ។

-គាត់ផ្ដាំថាម៉េចខ្លះ ? ថៅកែហ្វីឡាងសួរគាត់...

-គាត់ថាពេញចិត្តទាំងអស់ ឱ្យតែថៅកែចាត់ការពីនោះមកបាន
ស្រួល ហើយចំណែកពីនេះទៅភ្នំពេញ គាត់ប្រគល់លើក្រុមក្លូឡាប



សខ្ញុំនេះ ជាអ្នកចាត់ការតាមបញ្ជាគាត់ទាំងអស់ ។

ថៅកែហុងកុងទាំងពីរងក់ក្បាល ទើបស៊ីបេសួរម្ដង ÷

-ឯណាសំបុត្រដែលគាត់ផ្ញើមកយើងនោះ ?

ថាវីបើកកាបូប ឈ្ងោកបើរកសំបុត្រដែលថៅកែធំក្រុមក្លូឡាបស
ប្រគល់មកពីប៉ុន្មានថ្ងៃមុននោះ ស្រាប់តែនាងធ្វើភ្នែកឡឹងឡង់ មុខ
ស្លាំង បប្ញូរមាត់ញ័រទទ្រើក ញើសក៏សាយចេញជ្រោកៗមកក្រៅឡើង
ត្រជាក់ខ្លួនដូចគេយកទៅត្រាំក្នុងធុងទឹកកក ។ យល់អាកប្បកិរិយា
ប្រពន្ធដូច្នេះ ថៅកែមុយកាត់យល់ហេតុការណ៍ភ្លាម ក៏គំហកសួរឡើង
ភ្ញាក់សម្លេង ÷

-ឯណាសំបុត្រលោកថៅកែធំហ្ន៎ា ?

ថាវីរឹតតែស្លុតខ្លាំងថែមទៀត ÷

-បាត់...... បាត់......ស្រេចទៅហើយបង....... ។

ដូចរន្ទះបាញ់ចំកណ្ដាលអំបែងក្បាលទាំងអស់គ្នា គ្រាន់តែស្ដាប់
ពាក្យថាវីមួយឃ្លាខ្លីកំប៉ុកនេះ ។ ថៅកែប្ដីបញ្ឆក់កាបូបពីដៃ បើក្រ
ដាសប្រាក់បាចចេញប្រាវៗ តែពុំប្រទះសំបុត្រនៅក្នុងនោះសោះឡើយ
ហួសចិត្តថៅកែមុយបោកកាបូបប្រពន្ធប្រូសចោលទៅទៀត ហើយ
និយាយខ្លាំងៗថា ÷

-កាបូបកាន់ជាប់នឹងខ្លួនគ្រប់ពេល ហេតុម្ដេចក៏បាត់សំបុត្រកើត?

ថាវីនៅស្ងៀមកំពុងសញ្ជឹងគិត ទើបថៅកែហុងកុងម្នាក់បញ្ជាក់
ទៀត ÷

-នាងម្នាក់ឯងជាអ្នកទទួលខុសត្រូវ ក្នុងរឿងសំបុត្រស្នាមនេះ

ហើយបើសំបុត្រនេះធ្លាក់ដល់រាជការ មុខជាខូចការធំ ជាពិសេសទៅ ទៀតក្នុងសំបុត្រនោះមានហត្ថលេខា លោកចៅហ្វាយក្រុមក្លូឡាបស ផង ។ បើរាជការចាប់សំបុត្រនោះបាន ក៏ដូចជាចាប់លោកចៅ ហ្វាយធំនៅភ្នំពេញបានដែរ តើយើងត្រូវដោះស្រាយទៅដូចម្ដេចវិញ?

ចៅកែហុងកុងម្នាក់ទៀតឈ្មោះស៊ីបេ បន្ថែមមួយៗថា ÷

-រឿងនេះមិនមែនតូចទេ ! ទាំងអ្នកនៅភ្នំពេញ ទាំងអ្នកនៅខាង ហុងកុង នឹងត្រូវមានគ្រោះថ្នាក់ទាំងអស់គ្នា ព្រោះវាត្រូវបែកសំបុ ដោយសារសំបុត្រនោះមិនខាន ។ នាងនឹករកមើល ! តើនាងទុ ទៅឯណា ? ឬក៏ភ្លេចនៅឯណាទេដឹង ?

ថាវីងើបមុខឡើង ពោលដោយញ័រៗ ÷

-មុននឹងខ្ញុំឆ្លងមកនេះ ខ្ញុំបានបើកកាបូបមើលឃើញវានៅដដែល ហើយខ្ញុំមានការប្រុងប្រយ័ត្នជាងអ្នកណាទាំងអស់ ដូចពួកលោកថៅ កែធ្លាប់ទុកចិត្តខ្ញុំជាយូរមកហើយ ខ្ញុំមិនដែលប្រហែសធ្វើឱ្យខូចការម្ដ ណាឡើយ តែម្ដងនេះ......

ចៅកែមុយ សម្លឹងមុខប្រពន្ធទាំងគ្នាន់ក្នាញ់ ÷

-តែម្ដងនេះវាយ៉ាងម៉េច ? ឬមួយក៏ត្រូវវលាយសំណាងម្ដងនេ ហើយ ?

ថាវីឈ្ងោកមុខ តបមួយៗវិញ ÷

-ខ្ញុំដូចជារកនឹកមិនឃើញសោះ ព្រោះសំបុត្រវានៅក្នុងដៃ អម្បាញមិញហ្នឹងទេ បើសត្រូវវាមកលួច ក៏មិនដឹងជាលួចធ្វើម្ដេ កើតដែរ ព្រោះខ្ញុំកៀបតែនឹងក្លៀកជាប់ជាងរក្សាកូនតូចនៅក្នុងដៃ



ទៀត ហើយអ្នកប៉ះពាល់កាបូបខ្ញុំម្ដងមួយកាលមានតែបងមុយម្នាក់ ប៉ុណ្ណោះ........

ចៅកែមុយភ្ញាក់ក្រញាង ÷

-អូនចង់ថាបងជាអ្នកលួចសំបុត្រនោះលាក់ឬ ?

-ខ្ញុំមិនទាន់ហ៊ានថាចំនៅឡើយទេ តែវានៅក្នុងការសង្ស័យ រឿង នេះវាពិតឬមិនពិតក៏នៅក្នុងសំបុកយើងនៅឡើយដែរ ដូច្នេះដើម្បីឱ្យ ការនេះដើរទៅបានស្រួល យើងត្រូវតែឆែកបងមុយជាមុនសិន រួច សឹមឆែកអ្នកដទៃទៀត ។

ចៅកែមុយ គ្រវីក្បាលហួសចិត្ត ÷

-អីចឹងប្ដីប្រពន្ធយើង មានការមិនទុកចិត្តគ្នាទាំងស្រុងទៅហើយ មែនទេអូន ?

-ចំពោះស្នេហារវាងប្ដីប្រពន្ធនៅតែដដែល តែចំពោះកិច្ចការដ៏ធំ នេះ ត្រូវតែមិនទុកចិត្តគ្នាទើបបាន សូម្បីតែខ្លួនខ្ញុំក៏មិនទាន់ថាទុកចិត្ត ខ្លួនឯងឱ្យច្បាស់លាស់ទៀតផង ។

ចៅកែហុងកុងទាំងពីរ មិនយល់ស្ថានការណ៍ធ្វើមុខមឹងមាំងដូច មនុស្សពុលរលក ហើយបន្ទាប់មកថាវីរើបថ្កាល់ប្ដីសម្លាញ់មួយខ្សឹត ព្រមទាំងពោលតិចៗ ស្ទើរស្ដាប់មិនឮ ÷

-បងកុំព្រួយ សំបុត្រនេះអូនលាក់សិនហើយ ព្រោះមានមនុស្ស លបចូលមកស្ដាប់យើងដល់ទីនេះ.......

ចៅកែមុយ បើកភ្នែកធំៗ បញ្ឆាក់យ៉ាងរហ័ស ÷

-ម៉េចក៏អូនដឹង ?

-ចីមិនដឹង....... វាតាមយើងតាំងពីព្រឹកមិញម៉្លេះ ?

រួចថាវីរធ្វើជាលូកភាវរកសំបុត្រសព្វលើខ្លួនប្តី ហើយរំពេចនោះនាងហួចផ្អេកបីដងជាសញ្ញាទៅក្រៅ ស្រាប់តែមានស្នូរជើងមនុស្សរត់ភិបៗ ចូលមកដល់មួយរំពេចគឺនាយខិត នាយខី និងមិត្តវាបីនាក់ទៀត ។

ថាវីរចង្អុលទៅកន្សៀតថ្មជ្រុងខាងលិច ÷

-ទៅនាំមនុស្សម្នាក់ដែលគេចងទុកហើយស្រេចនោះចេញមក !

សហការីទាំងប្រាំពួន្ធច្នោះ ក៏ដូចជារន្ធត់ចិត្តបន្តិចដែរ ដោយមិនទឹកស្មានមានមនុស្សក្រៅ អាចចូលមកកាន់ទីនេះបាន ហើយត្រូវអ្នកយាមល្ហាងកោះចាប់បានសោះ ។ គេទាំងប្រាំធ្លាប់ជាអ្នកមានចិត្តលេងឆើតៗ ហើយធ្លាប់បំរើក្នុងក្រុមក្លូឡាបសនៅក្នុងក្រុងនេះ សឹងបានជោគជ័យគ្រប់អន្ទើ ប៉ុន្តែគេនឹកសរសើរចំពោះការប៉ិនប្រសប់របស់មនុស្សចាំល្ហាងនេះ ដែលពួកគេមិនដែលបានស្គាល់មុខម្តងសោះ មិនដឹងតើក្នុងនេះមានគ្នាប៉ុន្មាននាក់ ទើបពួកគេអាចធ្វើការទាក់ទងគ្នាពីក្នុងកោះទៅត្រើយនាយ ហើយរហូតទៅដល់លោកថៅកែធំមិនស្គាល់ឈ្មោះនៅឯរាជធានី បានឆាប់រហ័សខ្លាំងម៉្លេះ ? ប្រហែលជាក្រុមក្លូឡាបសមិនមែនមានតែពួកគេទេ គឺពិតជាអាះប្រើនពួកទៀត ដែលបំបែកគ្នាធ្វើការតាមរបៀបអាថ៌កំបាំង ដើម្បីកុំឱ្យមានការមន្ទិលសង្ស័យ ពីក្រសួងមានសមត្ថកិច្ចយើង ។

ពួកវាស្ទុះស្រទៅកាន់ទីងងឹតនោះបាត់ភ្លាមទៅ ទើបថៅកែស៊ុយសួរថាវីរដោយមុខស្លូត ÷



-ម៉េចក៏នាងដឹងថាមានគេចាប់មនុស្សទុកឱ្យនាងនៅកន្លែងហ្នុង ?

ថាវីរសើចបន្តិចយ៉ាងមានន័យ រួចញាក់ស្មាតប ÷

-កន្លែងនេះប្តីខ្ញុំ និងខ្ញុំ បានចាត់ចែងការស្រួលបួលណាស់ ពេលដែលពួកថៅកែចូលមកដល់ មានសំគាល់ឃើញពន្លឺភ្លើងពណ៌ក្រហមមួយនៅជ្រុងខាងហ្នុងទេ ?

-មាន ! ថៅកែទាំងពីរឆ្លើយព្រមគ្នា

-ភ្លើងក្រហមនេះហើយជាសញ្ញាក្នុងក្រៅសម្រាប់ពួកក្លូឡាបស ។ ឥឡូវថៅកែក្រឡេកមើលមើល៍ ! តើមានភ្លើងក្រហមហ្នឹងទៀតទេ ?

ថៅកែទាំងពីរ បែរមើលទៅកន្លែងនោះមួយភ្លែត ទើបងាកតបវិញ ÷

-ទេ ! រលត់បាត់ហើយ.......

-ហ្នឹងហើយជាសញ្ញារបស់អ្នកចាំក្នុងល្ហាងកោះនេះ ! បើកាលណាភ្លើងក្រហមរលត់ ដោយគ្មានពន្លឺផ្សេងជះប្តូរមកទេ នោះឱ្យដឹងថាសត្រូវចូលមកកាន់ទីនេះ ព្រមទាំងចាប់បានហើយ បើភ្លើងក្រហមរលត់ភ្លាម រួចមានពន្លឺផ្សេងទៀតជះចេញមកជំនួសនោះ បញ្ជាក់ឱ្យដឹងថាមនុស្សចំឡែកចូលមកហើយ តែចាប់មិនទាន់បានទេ ។

ថៅកែទាំងពីរងក់ក្បាលព្រមគ្នា ÷

-ចាត់ចែងបានល្អណាស់ ! តើមនុស្សនៅក្នុងកោះនេះមានប៉ុន្មាននាក់ សម្រាប់ធ្វើការឱ្យក្រុមក្លូឡាបស ?

ថៅកែសើចហើសៗ តបម្តង ÷

-នៅក្នុងទីនេះមានតែដប់នាក់គត់ ប៉ុន្តែសុទ្ធតែជើងឆើត អាចប្រើ

ការបានគ្រប់យ៉ាងទាំងអស់ ហើយពួកនេះគេប៉ិនដើរល្បិចបំផុត ទោះនៅកន្លែងណាក៏មានគេហ្នឹងធ្វើការដែរ ដូចជាអីវ៉ាន់ចេញពីកប៉ាល់បានឬមិនបានក្តី ក៏ពួកគេហ្នឹងជាអ្នកឱ្យសញ្ញាដឹងមុនទាំងអស់ ប៉ុន្តែគេមិនចេញមុខឱ្យអ្នកណាស្គាល់ទេ....... ។

-ម៉េចក៏អីចឹង ? ក្រែងពួកនេះជាបក្សពួករបស់ថៅកែហ្អី ?

-គេបំរើខ្ញុំជាស្រមោលប៉ុណ្ណោះ ព្រោះគេជាមនុស្សរបស់លោកថៅកែធំនៅភ្នំពេញ ដែលលោកចាត់មកឱ្យធ្វើការនេះជាមួយក្រុមកូឡាបសខ្ញុំដោយស្ងាត់កំបាំង មិនឱ្យស្គាល់មុខគ្នាទៅវិញទៅមកទេ ។

ហ៊ូឡាងថៅកែហុងកុងបញ្ជាក់តបថា ÷

-គួរឱ្យឆ្ងល់ដែរ ថៅកែធំនៅភ្នំពេញមិនដែលចេញមុខឱ្យអ្នកណាស្គាល់សោះ ធ្វើការអ្វីសុទ្ធតែតាមរយៈមនុស្សសម្ងាត់ៗរបស់គាត់ទាំងអស់ ដូចជាទៅទាក់ទងជាមួយខ្ញុំនៅហុងកុងក្តី គាត់បញ្ជូនតែមនុស្សដទៃឱ្យទៅជំនួស ចំណែករូបគាត់វិញខ្ញុំមិនដឹងជាមុខមាត់ដូចម៉េចភ្នែកគាត់យ៉ាងណាទេ...... ។

-សូម្បីតែកូឡាបសខ្ញុំនៅឯណោះ ដែលធ្វើការផ្ទាល់ជាមួយគាត់ ក៏គាត់មិនដែលឱ្យស្គាល់មុខដល់ម្តងផងទេ បើត្រូវការបញ្ជាអ្វីៗ សុទ្ធតែប្រើសំបុត្រតាមមនុស្សអំពិលអំពែករបស់គាត់ទាំងអស់ (ថៅកែមុយបន្ថែម) ជួនកាលគាត់មកនៅក្បែរៗតែពួកឯងហ្នឹងដែរ ហើយមានពេលខ្លះទៀតគ្រាន់តែការអ្វីដែលខ្ញុំប្រុងធ្វើ គាត់តែងព្រមានមុនស្រេច

ថាវីរសម្បឹងទៅកន្លែងសហការីចូលទៅអម្បាញមិញបន្តិច ទើបបន្តពីប្តីទៀត ÷



-ជួនកាលគាត់ចាត់គេឱ្យមកហៅខ្ញុំ ទៅជួបគាត់នៅឯភ្នំពេញ ប៉ុន្តែយើងជួបគ្នាតែតាមទូរស័ព្ទប៉ុណ្ណោះ ។ គួរឱ្យឆ្ងល់មួយទៀត គឺអ្នកដែលនិយាយទូរស័ព្ទជាមួយខ្ញុំនោះ មិនមែនជាប្រុសដូចយើងស្មាននោះទេ គឺពិតជាស្រី ហើយដល់ខ្ញុំសួរដេញដោលគាត់ណាស់ទៅ គាត់ឆ្លើយមកខ្ញុំវិញថា គាត់នៅក្បែរៗខ្ញុំហ្នឹងឯង កុំបាច់ចង់ស្គាល់អីចាំផែនការណ៍ធំមួយនេះសម្រេច សឹមជួបជុំគ្នាម្តង ។

-អីចឹងថៅកែធំរបស់ក្រុមកូឡាបសជាស្រីទេ ? ស៊ីបេសួរបញ្ជាក់

-បាស ! បើតាមខ្ញុំយល់គឺស្រីមែន ប៉ុន្តែមិនដឹងជាគាត់រស់នៅកន្លែងណា ហើយមានសម្បត្តិទ្រព្យប៉ុណ្ណា ទើបគាត់អាចជះប្រាក់ចាត់ការនេះបានធំដុំម្ល៉េះ....... ។

ថៅកែមុយជាប្តីបញ្ចេញសំដីបន្តពីប្រពន្ធទៀត ÷

-យើងគង់តែបានស្គាល់គាត់ ក្នុងពេលឆាប់ៗនេះទេ ព្រោះគាត់បានសន្យាថា ដល់បញ្ហាធំមួយនេះដោះស្រាយរួចហើយ គាត់នឹងចេញមកបង្ហាញពួកយើងស្គាល់មិនខានឡើយ ។

ខណៈនោះ ក្រុមនាយខ្ទិតក៏អូសមនុស្សជាប់ចំណងម្នាក់ ចេញពីទីងងឹតមកបោះពីមុខថៅកែទាំងអស់ ។ បុរសនេះស្លៀកពាក់ខោអាវជាអ្នកនេសាទធម្មតា ហើយនៅសន្លប់ពុំទាន់ដឹងខ្លួននៅឡើយផង ទោះបីត្រូវពួកនោះអូសមកបោះទីងណាត់ទីងណែង ក៏ជននោះនៅតែមិនទាន់ដឹងខ្លួនដដែល ។

ថាវីសួរទៅនាយខ្ទិតទាំងចងចិញ្ចើម ÷

-វាសន្លប់ដោយគេវាយ ឬមួយវាយ៉ាងម៉េចហ្នឹង ?

នាយខិតសម្លឹងជនជាប់ចំណងបន្តិច ទើបឆ្លើយ ÷

-មិនឃើញមានស្នាមរបួសបន្តិច ដែលអាចបណ្ដាលឱ្យវាសន្លប់ទេ អ្នកស្រី...... ។

-អីចឹងមានតែគេប្រើថ្នាំ ដូច្នេះខិតឯងទៅយកទឹកបន្តិចមក !

នាយខិត ដើរទៅយកទឹកមួយថង់កៅស៊ូមកស្រោចលើក្បាលជននោះ ហើយចាប់ក្បាលគ្រវីចុះឡើងបន្តិចៗ រហូតដល់បុរសនោះភ្ញាក់បើកភ្នែកព្រិមៗ សម្លឹងទិដ្ឋភាពជុំវិញខ្លួន ព្រមទាំងថ្ងូរតិចៗ ទាំងរវើរវាយ ÷

-អួយ....... ខ្ញុំនៅឯណា........ឆ្មាមស៊ីខ្ញុំហើយទេដឹង.......ពុទ្ធោអើយ...... ខ្ញុំប្រាស់ព្រាត់បងប្អូនអស់ហើយ....... ។

នាយខិតទះកំផ្លៀងពីរបីដៃស្រាលៗ បណ្ដាលឱ្យនាយនោះស្វាងមុខថែស ហើយគ្រវីក្បាលយឺតៗ សម្លឹងមនុស្សទាំងអស់ដែលឈរក្បែរខ្លួន ដោយអាការៈភិតភ័យក្រៃលែង ។ នាយរងគ្រោះលើកដៃសំពះម្ចាស់ល្អាងយ៉ាងទន់ភ្លន់ ÷

-សូមអស់លោកទទួលនូវសេចក្ដីអំណរគុណ យ៉ាងជ្រាលជ្រៅពីខ្ញុំមួយជីវិតនេះខ្ញុំមិនភ្លេចគុណអស់លោកទេ ដែលបានជួយយកអាសារខ្ញុំឱ្យផុតពីសេចក្ដីស្លាប់នៅក្នុងសមុទ្រ តើកន្លែងនេះនៅឯណាទៅ ?

ថាវីសម្លឹងមុខយុវជនមិនស្គាល់ឈ្មោះនេះយ៉ាងមុត ហើយទំនងជាមានន័យប្លែកជាងពីដំបូងឆ្ងាយណាស់ ។ រូបសម្ផស្សរបស់យុវជនព្រមទាំងផ្លូងនេត្រាភ្លឺថ្លាដូចពេជ្រទាំងគ្រាប់ បានចាប់កន្ត្រាក់ដួងព្រលឹងនាងឱ្យញាប់ញ័រដោយមិនដឹងខ្លួន នេះជាទឹកចិត្តធម្មតារបស់



ស្រីចិត្តវាល់ពាន់ក្នុងលោកប៉ុណ្ណោះ ។ នាងថាវីងាកមុខទៅមើលប្ដីចាស់បន្តិច រួចបែរទៅកាន់នាយខ្វីស្រដីថា ÷

-ខ្វីឯងសួរគេទៅមើល ! ហេតុយ៉ាងណាបានជាគេឆ្លងមកកាន់កោះពស់នេះទាំងយប់អីចឹង ?

នាយខ្វីទទួលបញ្ជា ហើយក៏ដើរមកចាប់សក់យុវជន ដោយបោះសំនួរធ្ងន់ៗថា ÷

-គាត់ឯងនៅភូមិណា ?

នាយរងគ្រោះ វេភ្នែកសម្លឹងមនុស្សកោះ ទាំងភិតភ័យសស្លឹតសស្លក់ ÷

-បាទ....... ខ្ញុំនៅឯភ្នំភ្ជីមាស [១] លោក.......

-ភូមិភ្ជីមាស ? តើមកកោះពស់នេះធ្វើអ្វី ?

ស្រាប់តែនាយនោះបើកភ្នែកធំៗ និទានឡើងទាំងភ្ញាក់ ÷

-ខ្ញុំមកដល់កោះពស់ ! យី........ ខ្ញុំអណ្ដែតមកឆ្ងាយណាស់ពុទ្ធោអើយ....... ពិតជាវាសនាខ្ញុំនៅខ្ពស់ណាស់ ទើបបណ្ដាលឱ្យខ្ញុំបានរួចពីសេចក្ដីស្លាប់យ៉ាងនេះ ដូច្នេះអស់លោកនេះជាអ្នកជួយស្រង់ខ្ញុំពីក្នុងទឹកមកមែនទេ ? បើដូច្នោះមែនខ្ញុំសូមថ្លែងអំណរគុណម្ដងទៀត....ហើយខ្ញុំពុំដឹងជាបានពាក្យអ្វីនឹងថ្លែងឱ្យហួសពីប៉ុណ្ណឹងទេ.......

ថាវីសម្លឹងមុខយុវជនរូបស្អាតបន្តិច ក៏បោះសំនួរបន្ថែម ÷

-និយាយឱ្យអស់មើល៍ ! តើហេតុយ៉ាងណាបានជាគាត់ឯងចូលមកក្នុងកោះនេះកើត ?

---

១- ភូមិភ្ជីមាសនៅត្រើយម្ខាងសមុទ្រទៅខាងដីកោះកុង

នាយរងគ្រោះលើកដៃអេះក្បាល ដូចជារកនឹកអ្វី មួយសន្ទុះទើបតប ÷

-កាលពីថ្ងៃ ខ្ញុំជាមួយបងប្អូនបួននាក់ នាំគ្នាធ្វើដំណើរដោយទូកម៉ាស៊ីនពីកោះកុងតម្រង់មកកាន់ភូមិនេសាទ ដើម្បីនាំយកត្រីយកមកឱ្យគេ ស្រាប់តែមិនដឹងជាចៃដន្យអីក៏ប៉ះលើខ្យល់ព្យុះ យ៉ាងធំចំកន្លែងឆ្លងកាត់មុខកោះនេះ បណ្ដាលឱ្យលេចទូកខ្ញុំតែម្ដង ហើយខ្ញុំក៏ស្រវារបានបន្ទះក្ដារតោងបណ្ដែតខ្លួន មករកកោះនេះ ដែលមើលឃើញនៅជិតជាងគេ ប៉ុន្តែដោយខំយោងខ្លួនហួសកំឡាំងពេក ទើបខ្ញុំសន្លប់បាត់ស្មារតីលែងដឹងអីពីពេលនោះមក ហើយឯបងប្អូនខ្ញុំបីនាក់ទៀតមិនដឹងជាស្លាប់ឬយ៉ាងណាទេ.......ហេតុម្ដេចទើបខ្ញុំត្រូវជាប់ចំណងដូច្នេះ តើខ្ញុំមានកំហុសអ្វី ?

ថៅកែមុយសម្លឹងមុខយុវជនរងគ្រោះយ៉ាងមុត រួចងាកមកនិយាយថា ÷

-ចំពោះប្រយោគទាំងប៉ុន្មានរបស់គេ យើងអាចយល់បានថា គេមិនមែនជាមនុស្សដែលយើងត្រូវសង្ស័យនោះទេ ប៉ុន្តែដើម្បីឱ្យមានការប្រុងប្រយ័ត្នជានិច្ច យើងមិនត្រូវដោះលែងទៅវិញភ្លាមទេ យើងត្រូវឃុំមនុស្សនេះទុកមួយកន្លែងសិន ហើយបើកាលណាយើងបានពត៌មានពិតថាមានទូកលិចមែននោះ សឹមយើងដោះលែង ។

ទាំងអស់គ្នាងក់ក្បាល យល់តាមសំដីអារកាត់របស់លោកថៅកែ រួចថាវីបែរទៅនិយាយប្រាប់ថៅកែហុងកុងទាំងពីរ ÷

-ម៉ោង ១១បន្តិចទៀតនេះ យើងត្រូវទៅជួបគ្នានៅឯបារក្លឹបស



ដើម្បីរង់ចាំទទួលសំបុត្រអាថ៌កំបាំង ពីលោកថៅកែធំមកពីភ្នំពេញហើយនឹងកិច្ចការផ្សេងៗទៀត ដែលយើងចាំបាច់ត្រូវតែដោះស្រាយឱ្យហើយ ក្នុងពេលនេះ ។

ថៅកែស៊ីបេនិងហ្វីឡាងងក់ក្បាលផ្ងក់ៗ ÷

-អីចឹងអនុញ្ញាតឱ្យខ្ញុំ ចេញពីកន្លែងនេះមុនបានទេ ?

-សូមអញ្ជើញទៅមុនចុះ តែតោងប្រុងប្រយ័ត្នឱ្យមែនទែន ព្រោះឥឡូវនេះមានមនុស្សប្លែកៗ តាមពួកយើងច្រើនណាស់ ។

ថៅកែទាំងពីរងក់ក្បាលដើរចេញទៅយ៉ាងលឿន ដោយមានសហការីក្លឹបសម្នាក់បំភ្លឺផ្លូវឱ្យផង ហើយបន្ទាប់មកថាវីងាកមកកាន់នាយខ្វី ÷

-ខ្វីឯងចងមនុស្សនេះផ្ដាប់នឹងគោអីឱ្យពួកល្ហាងកោះវិញចុះ ហើយបើយើងស៊ើបទៅដឹងថាគេជាមនុស្សគ្មានបំណង ប៉ះពាល់លើក្រុមយើងទេនោះ ចាំយើងដោះលែងឱ្យគេត្រឡប់ទៅវិញ ។

យុវជនធ្វើមុខមឹងម៉ាំង ដោយមិនយល់ចំពោះអាកប្បកិរិយាមនុស្សមួយក្រុមនេះ មិនដឹងជាគេមានបំណងយ៉ាងណាលើរូបនាយ ហើយបើនិយាយអង្វរគេក៏ពុំបានការដែរ ដូច្នេះគេត្រូវទ្រាំទៅតាមវាសនាទៅចុះ.......

ថៅកែមុយនិងនាងថាវីជាប្រពន្ធ ប្រុងនឹងឈានជើងនាំក្រុមក្លឹបសត្រឡប់ចេញទៅវិញហើយ ស្រាប់តែមានស្រមោលមនុស្សហក់ភ្លែតចេញពីជ្រុងម្ខាង គេចទៅពួននៅជ្រុងម្ខាងទៀតលឿនដូចផ្លេក បណ្ដាលឱ្យពួកនេះទុចជំហានង៉ក់ ងាកមើលមុខគ្នាឡឹងឡង់

តែថាវីរីប្រញាប់ស្រែកទៅថា ÷

-ក្រុមសម្ងាត់រក្សាល្អាងកោះពស់នេះ ឬអ្នកណា ?

ស្ងាត់ឈឹង ! ពុំមានសម្លេងអ្វី ឬសម្រិបអ្វីបន្តិចតបមកវិញក្រៅពីស្នូរទឹករលកបោកផ្ទប់ថ្មលាន់ឆាៗ ឯជើងកោះនោះឡើយ បណ្ដាលឱ្យពួកគេព្រឺក្បាលសំពោងគ្រប់គ្នា ។

ថៅកែមុយលូកដៃចូលក្នុងហោប៉ៅខោ ហើយស្រែកខ្លាំងៗ ÷

-ក្រុមសម្ងាត់របស់ក្វូឡាបស ទេឬអី ?

រិតតែបុកពោះណាស់ទៀត ! ព្រោះគ្មានសម្លេងអ្វីក្រៅពីសម្លេងខ្ទ័រចេញពីល្អាងកោះ ឆ្លើយឆ្លងតបមកវិញឡើយ បណ្ដាលឱ្យពួកនេះកាន់តែសភ្នែកមែនទែន ដោយគិតថា បើស្រមោលនេះជាមនុស្សសម្ងាត់នៅក្នុងល្អាងនេះ ឬជាមនុស្សសម្ងាត់ខាងក្រុមក្វូឡាបស គង់តែមានឱ្យសញ្ញាដឹងជាមិនខាន ។

នាយខ្វីហាក់ភ្លែតមកឈរពីមុខ វាសពន្លឺពិលភ្លែតៗ ជាច្រើនសារតែពុំអាចទំលុះថ្មទៅមើលពីក្រោយបានឡើយ ម្ល៉ោះហើយការមិនទុកចិត្តក៏កាន់តែលេចច្បាស់ឡើងក្រឡែតចំពីមុខ ប៉ុន្តែពួកគេនឹកថា បើមានសត្រូវឈ្លានពានចូលមកកាន់ទីនេះ ក៏ច្បាស់ជាគេចមិនរួចពីភ្នែកមនុស្សសម្ងាត់រក្សាល្អាងកោះនេះដែរ ដែលគេធ្លាប់បញ្ចេញការប៉ិនប្រសប់ ឱ្យឃើញជាច្រើនដងរួចមកហើយ ។

ថៅកែមុយមិនអស់ចិត្ត ដកខ្សៀចេញពីមាត់ស្រែកបញ្ចេញសម្លេងខ្លាំងៗ ÷

-ឆ្លើយភ្លាមមក អ្នកនៅខាងក្រោយថ្ម ប្រយ័ត្នយើងបាញ់ណា !



HUN SEN LIBRARY R.U.P.P. បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ផុតសម្លេងថៅកែ ស្រមោលមនុស្សម្នាក់ហាក់ភ្លែតមកឈរស្កុបពីមុខអ្នកទាំងនោះ ដោយនៅដៃមានកាន់កាំភ្លើងខ្លីខ្មៅរលោងចាំងនឹងពន្លឺភ្លើងព្រាកៗ បញ្ចេញមាត់គ្រែក្រហតចំមករកខ្លួនផង បណ្ដាលឱ្យក្រុមថៅកែមុយភ័យស្រឡាំងកាំង ដូចរន្ទះបាញ់ចំសន្ទះក្បាល ។

-ជំរាបសួរថៅកែក្វូឡាបស ! យើងតាមមករកសួរសុខទុក្ខថៅកែដល់ទីនេះ ដោយពុំបានជំរាបជាមុន សុំថៅកែអភ័យទោស ! ប្រហែលជាថៅកែធ្លាប់ស្គាល់មុខយើងដែរហើយមែនទេ ?

ថៅកែមុយស្រឡាំងកាំង ថាវីរីញ័រដៃ នាយខ្វីនាយខិត ឈរទ្រឹងប្រឹងសម្លក់មើលមុខជនកាន់កាំភ្លើងយ៉ាងយកចិត្តទុកដាក់ ស្រាប់តែថាវីរីលាន់មាត់ ÷

-សែហ្វភីនទេតើ ! សែហ្វឆ្លងមកកោះនេះធ្វើអ្វីដែរ ?

-ហាៗ ! សួរអីចឹងដូចជាមិនសមសោះ អ្នកស្រីដឹងថាខ្ញុំធ្វើជាអ្វីទេ ? ហើយខ្ញុំខំតាមដានមកដល់ទីនេះទាំងយប់ងងឹតមិនខ្លាចគ្រោះថ្នាក់ មិនខ្លាចបង់ងងុយ មិនតីករណីយកិច្ចរបស់ខ្ញុំទេឬ ?

កូនចៅថៅកែមុយកម្រើកខ្លួនគ្រប់គ្នា ហាក់ដូចទើបភ្ញាក់ស្មារតីពីសន្ទប់ប្រុងនឹងស្ទុះមកតតាំង តែ ÷

-កុំកម្រើកខ្លួនទៀត ! នៅឱ្យស្ងៀម ! បើមិនស្ដាប់ទេ គិតខានឃើញមុខប្រពន្ធហើយ !

បញ្ញាដាច់អហង្ការរបស់សែហ្វភីន ភ្នាក់ងារសម្ងាត់ទីពីររបស់បុរសពិសេសយើង បានធ្វើឱ្យពួកថៅកែមុយលែងហ៊ានកម្រើកខ្លួនទៀត តែនាងថាវីរីដែលធ្លាប់មានការទាក់ទងជាមួយសែហ្វយើង នេះពីមុនៗ

ខ្វះដែរ ក៏ខំសម្រួមចិត្តលេបទឹកមាត់បំបាត់ការញាប់ញ័រ ហើយបើកមាត់សួរវិញ ÷

-សែហ្វមកកាន់ទីនេះ តើមានបំណងអ្វីដែរ ? ហើយតើពួកខ្ញុំមានទោសអី ទើបបានសែហ្វលើកកាំភ្លើងភ្ជង់យ៉ាងនេះ ?

ចុងកាំភ្លើងសែហ្វភីននៅនឹងថ្កល់ តែភ្នែកគាត់បាញ់យ៉ាងមុតមករកម្ចាស់សំនួរ រួចរេកន្ទុយភ្នែកមួយខ្ទាប់ទៅលើមនុស្សគ្រប់រូប ÷

-ខ្ញុំតាមដានអ្នកស្រីមកយូរហើយ ទើបតែពេលនេះខ្ញុំបានដឹងថាអ្នកស្រីមិនមែនជាអ្នករកស៊ីធ្វើបារត្រឹមត្រូវទេ ។ អ្នកស្រីនិងប្ដីបានប្រព្រឹត្តផ្ទុយនឹងច្បាប់សម្រាប់រដ្ឋពេញទី គឺអ្នកស្រីបានបង្កើតបក្សពួកដើម្បីរកស៊ីផ្លូវងងឹត បំបិតភ្នែកក្រសួងមានសមត្ថកិច្ចយើង ។ ឥឡូវខ្ញុំមិនបាច់និយាយច្រើនទេ សុំតែអ្នកស្រីប្រគល់សំបុត្រថៅកែធំរបស់អ្នកស្រីពីភ្នំពេញមកខ្ញុំមុនមក ! ហើយបន្ទាប់មក ខ្ញុំសុំអញ្ជើញអ្នកទាំងអស់ទៅកាន់ស្នងការដ្ឋានក្រុង ដើម្បីឆ្លើយចំពោះមុខលោកស្នងការចុះ !

ថាវីនិងថៅកែមុយ បើកភ្នែកធំៗមើលមុខគ្នា រួចទើបថៅកែមុយសួរវិញធ្វើហាក់ដូចជាមិនដឹងខ្លួន ÷

-សែហ្វមករកសំបុត្រអីកន្លែងនេះ ? ចាំតង់បារខ្ញុំនោះឬ ?

-ហាំៗ ! ខ្ញុំមកទារចាំតង់ ? ខ្ញុំគ្មានមកប៉ះពាល់ពីរឿងចាំតង់របស់ថៅកែនោះទេ ខ្ញុំមកនេះដោយចង់ដឹងថា តើពួកបារកូឡាប-សមកលើកោះនេះដើម្បីធ្វើអ្វីទេតើ ? ឥឡូវខ្ញុំឮថាពួកថៅកែមានទាក់ទងក្នុងរឿងរត់ពន្ធអីវ៉ាន់បរទេស ចូលមកក្នុងស្រុកដោយលួចលាក់ប៉ុន្តែមិនទាន់ដឹងជាអីវ៉ាន់នោះមកដល់ហើយឬនៅ សុំថៅកែទៅឆ្លើយឯស្នងការចុះ ព្រោះខ្ញុំមានភារៈតែត្រឹមចាប់បញ្ជូនខ្លួនក្រុមថៅកែប៉ុណ្ណោះទេ........



ពោលដូច្នោះហើយ សែហ្វភីនដើរចូលមកមួយជំហានទៀតដោយតម្រង់ចុងកាំភ្លើងមកបំទ្រូងថៅកែគ្មានរេ ។ ខណៈនោះនាយខ្វីរែបដូចជាចង់យកគាប់ចៅហ្វាយ ក៏ហក់ភ្លែតរហ័សដូចខ្លា ប្រុងទៅសង្គ្រុប់ភ្នាក់ងារសម្ងាត់យើង....... តែ......ប៉ុង ! អូយ !......

ផុតសម្រែក រូបនាយខ្វីក៏រលំត្លុងទៅ ដោយមានលោហិតហូរភលៗ ចេញពីទ្រូងគួរឱ្យស្ញើបក្រៃលែង ។

-យើងបានព្រមានហើយតើ ! ម្នាក់ៗកុំកម្រើកខ្លួនដោយយើងមិនទាន់បញ្ជាឱ្យសោះ ហើយបើហ៊ានល្មើស នឹងបានទទួលលទ្ធផលដូចម្នាក់ហ្នឹងអីចឹង !

អ្នកឯទៀតនៅរឹងតាំង ភាំងសតិស្ទើរបាក់ស្មារតី កាលបើយល់សហការីបំរះននៀលក្នុងថ្លុកឈាមរីវក់ ដូចត្រីរស់ត្រូវមួយខ្នងកាំបិតហើយភ្នាក់ងាររបស់បុរសពិសេស ចេញបញ្ជាដោយពាក្យម៉ាត់ៗទៀត ÷

-ត្រូវលើកដៃឡើងលើ ហើយបែរមុខទៅជញ្ជាំងថ្មភ្នាមទៅ !

ជនទាំងប្រាំមួយរូប ប្រតិបត្តិតាមឥតហ៊ានរឹងទទឹងទៀតឡើយ រួចហើយទើបសែហ្វភីនឆែកក្នុងខ្លួនជនម្នាក់ៗ យកកាតនិងអាវុធផ្សេងៗ ។ ក្នុងចំណោមនោះមានតែនាងថាវីទេ ដែលមានកាំភ្លើងខ្លីធុនតូចស្វ័យប្រវត្តិនៅក្នុងកាបូប ឯជនដទៃទៀត មានតែកាំបិតមួយៗ

ម្នាក់ប៉ុណ្ណោះ ។ លុះរើយកវត្ថុត្រូវការបានគ្រប់សព្វហើយ ទើបសែហ្វភីនរុញចុងកាណុងផ្ទឹបជាប់ពីក្រោយខ្នងថៅកែមុយ ហើយប្រាប់ថា ÷

-ត្រូវគាត់ឯងបញ្ជាបក្សពួកទាំងប៉ុន្មាននេះ ឱ្យដើរចេញទៅមុខទៅ ហើយយើងសុំប្រាប់ថា បើពួកនោះមិនស្តាប់ទេ យើងត្រូវតែសម្លាប់ថៅកែឯងមុនគេ ស្តាប់បានហើយឬនៅ ?

ថៅកែមុយជាមនុស្សអន់ស្មារតីស្រាប់ ក៏តាំងភ័យសស្លឹតសស្លក់ ហើយមានដៃករឹងៗបុកចំឆ្អឹងខ្នងពីក្រោយ ឡើងស្រៀវខ្លួនចង់ក្រុចញាក់ គាត់ក៏ប្រាប់ទៅបក្សពួកនិងប្រពន្ធដោយញ័រៗ ÷

-អូនថាវី........ ត្រូវអូនឯងនាំគ្នាដើរមុនទៅ ហើយមិនត្រូវឱ្យពួកវាធ្វើផ្តេសផ្តាសទៀតទេហ្ន៎ !

ថាវីបែរក្រោយទាំងខាំមាត់ ក្តាន់ក្តាញ់ក្នុងចិត្ត ព្រោះនាងបានដើរលេងច្រើនប្រទេសហើយ មិនដែលមានអ្នកណាមកបញ្ជានាងបានងាយៗដូច្នេះសោះ ទើបតែម្តងណេះ ត្រូវភ្នាក់ងារសម្ងាត់បើកសំឡុតឱ្យធ្វើតាមបានដូចគ្រឿងយន្ត ។

សែហ្វភីនបណ្តើរអ្នកទាំងនោះ មិនទាន់ទាំងចេញផុតមាត់ល្អាងផងស្រាប់តែមានស្រមោលមួយហក់ភ្លែត មកពីក្រោយស្រាលស្ទើកដូចសំឡី ហើយលើកវត្ថុមួយរាងវែងដូចដំបង សំពងចំកញ្ចឹងកសែហ្វយើងលាន់ផស ! ដូចភ្នំផ្ទុះ បណ្តាលឱ្យសែហ្វយើងទន់ជង្គង់ដួលក្រិបសន្លប់បាត់មាត់ឈឹង លែងកំរើកខ្លួនតែម្តង ហើយស្រមោលជនអប្រិយនោះក៏ភៀសខ្លួនភ្លែតបាត់ទៅវិញ ដោយពុំមានឱ្យយើងអាចសំគាល់រាងរៅ ឬមុខមាត់ឃើញយ៉ាងណាឡើយ ។ ក្រុមថៅកែមុយងាកយ៉ាងរហ័សមកវិញ ក៏បញ្ចេញញញឹមដាក់គ្នាយ៉ាងរីករាយ ហើយថាវីបញ្ជាទៅដៃជើងថា ÷



-អូសទៅចងទុកខាងក្នុងសិនទៅ ចាំយើងសម្រេចការធំដុំនៅឯលើហើយ សឹមយើងមកដឹកគាត់នេះយកទៅបណ្តែតចោលឯកណ្តាលសមុទ្រឱ្យឆ្លាមស៊ីវិញម្តង !

ពួកគេនាំគ្នាសែងភ្នាក់ងារយើង ចូលទៅចងភ្ជាប់នឹងបង្គោលឈើមួយ ដែលគេដាំទុកសំរាប់ប្រើការផ្សេងៗ នៅក្នុងល្អាងនោះយ៉ាងជាប់មុឹង ទើបថៅកែស្រែកឡើងថា ÷

-យើងសុំអរគុណណាស់ ដែលម្ចាស់ល្អាងបានជួយស្រោចស្រង់ពួកយើង ឱ្យរួចផុតពីទុក្ខភ័យក្នុងពេលនេះ ហើយយើងនឹងសរសេរសំបុត្រ ទៅជូនលោកធំឯភ្នំពេញទៀត ដើម្បីឱ្យលោកជ្រាបពីបេសកកម្ម ដែលពួកលោកបានបំពេញយ៉ាងប្រសើរនៅក្នុងក្រុងព្រះសីហនុនេះ !

ពុំមានសម្លេងមនុស្សឆ្លើយមកវិញទេ តែគេទាំងអស់គ្នាយល់ថាទោះបីយ៉ាងណាក៏ពួកក្លូឡាប-សង់ក្លាហាននោះ បានឮច្បាស់នូវសំដីគេទាំងប៉ុន្មាននេះដែរ ទើបគេនាំគ្នាចេញពីល្អាង តម្រង់ទៅកាណូតជាប្រញាប់ ដោយមាននាយខ្វិតជាអ្នកបំភ្លឺផ្លូវ ។ មួយស្របក់កាណូតក្រុមថៅកែមុយ ក៏បាកចេញពីកំពង់កោះសំដៅឆ្ពោះទៅកាន់ភូមិនេសាទ ដោយគេនាំគ្នាប្រែភេទជាអ្នកនេសាទធម្មតាវិញ ដើម្បីកុំឱ្យក្រុមល្បាតចាប់ការសង្ស័យ ។

កាណូតផ្ទុកជនទុច្ចរិតជិតមកដល់ច្រាំង ស្រាប់តែមានកាណូតតូចមួយរត់ត្របាញ់លើទឹក តម្រង់ភ្លើងហ្វាចំមក ហើយតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ កាណូតតូចនោះក៏មកបញ្ឈប់ចម្ងាយប្រហែលបីម៉ែត្រ ពីកាណូតថៅកែមុយ ទើបគេអាចស្គាល់ជាក់ជាកាណូត យាមល្បាតរបស់ក្រុមគយ ។

សម្លេងមួយស្រែកសួរថា ÷

-ពួកអ្នកឯងមកពីខាងណាហ្នឹង ?

នាយខ្ទិតដែលឈរខាងមុខ ងើបក្បាលឆ្លើយ ÷

-ពួកខ្ញុំទៅរកទទួលត្រីពីគេនៅឯកោះវង្ក តែដោយយប់នេះគេមិនបានចេញទៅនេសាទ ទើបពួកខ្ញុំឆាប់បានវិលត្រឡប់មកវិញទាន......

ឮដូច្នោះហើយ កាណូតគយក៏ត្រលប់ក្រោយវិញយ៉ាងលឿន ដោយពុំមានចាប់ពិរុទ្ធសង្ស័យ ទៅលើការក្លែងខ្លួនរបស់ក្រុមថៅកែមុយនេះសោះ ព្រោះធម្មតាអ្នកនេសាទតែងចេញចូលកំពង់ មិនថាពេលណាជាពេលណាឡើយ ។ ក្រុមថៅកែមុយមានចិត្តត្រេកអរណាស់ ក៏បញ្ជាកាណូតឱ្យចូលទៅចតនៅកំពង់ ហើយថៅកែមុយនិងថាវីរីនាំគ្នាលោតចុះទៅលើខ្សាច់ជាប្រញាប់ ។ មុននឹងចាកចេញពីកំពង់ ថាវីរីបានផ្តាំទៅសហការីនៅក្នុងកាណូតថា ÷

-ខ្ទិតឯងត្រូវនៅចាំទទួលបញ្ជាផ្សេងៗ ទីនេះហើយ ព្រោះចាប់ពីស្អែកនេះទៅ ពួកយើងត្រូវមានការបំពេញច្រើនណាស់ ហើយជាពិសេសត្រូវតែស្តាប់ដំណឹងពីកោះពស់ឱ្យបានគ្រប់ម៉ោងឮទេ ?

-បាទអ្នកស្រី ! ពួកខ្ញុំរង់ចាំបញ្ជាគ្រប់ពេលវេលា សូមតែអ្នកស្រីចាត់ការខាងលើនោះឱ្យបានស្រួលចុះ.......



ថៅកែមុយនិងប្រពន្ធបណ្តូលចិត្ត ដឹកដៃគ្នារត់លើខ្សាច់ឆ្ពោះទៅកាន់រថយន្តតូយោតា ដែលទុកចោលនៅក្រោមដើមស្រល់ជិតនោះ ហើយមួយសន្ទុះរថយន្តទំនើបនោះក៏ល្បូនខ្សៀកៗ ឡើងទៅកាន់ផ្លូវធំ ដោយថៅកែជាអ្នកបញ្ជាចង្កូត ។ ថាវីរីរុញច្រមុះមកថើបថ្ពាល់ប្តីបន្តិច ÷

-បងហ្នាំ ! អម្បាញមិញខ្ញុំស្មានថាអាសន្នធំចូលលុកហើយតើ....

-អូនភ័យទេ ?

-ភ័យដែរ........ តែដូចជាមិនសូវប៉ុន្មានទេ ព្រោះយើងមានគ្នាសន្ទឹកសន្ធាប់ប៉ុណ្ណឹងដែរ មិនដឹងជាឱ្យមនុស្សម្នាក់មកសំឡុតបានទទេៗយ៉ាងម៉េចទេបង !

ថាវីរី សើចកាច់កទម្លាក់ក្បាលលើស្វាមីដោយចិត្តសោមនស្សរួចហាត្ថាដ៏តូចល្វតល្វន់ ក៏បានលើកលើងអង្អែលក្បាលប្តីសម្លាញ់ទាំងធ្មេចភ្នែកព្រិមៗ ញញឹមព្រាយមុខរីកពព្រើម ។ ថៅកែទប់ចង្កូតដៃមួយ ដៃមួយទៀតក៏បញ្ជាឱ្យមកអង្អែលកេសាប្រពន្ធបណ្តូលចិត្ត រួចធ្លាក់រហូតមកដល់ក្នុងអាវប្រចាប់នេះបន្តិច នោះបន្តិច រួចដៃដ៏ចង្រៃនេះធ្លាក់ចុះរហូតដល់គល់ភ្លៅទៀត ។ ហើយស្អីៗក៏ថៅកែភាវខ្មៅចខ្វីគ្មានទុកឱ្យទំនេរដែរ........ ។

## ២

# មហាឃាតកម្មបិទមុខ

**រថយន្ត**លូនត្រៀនៗ កាត់មុខសាលាក្រុងសំយុងចុះភ្នំរហូតមកដល់មុខអនុវិទ្យាល័យ ទាំងប្រពន្ធទាំងប្ដីកំពុងតែបណ្ដែតអារម្មណ៍ឱ្យឡើងទៅកាន់ស្ថានសួគ៌ ស្រាប់តែមានសំលេងមួយណែនធ្ងន់ដាច់អហង្ការបញ្ជាពីក្រោយខ្នង ៖

-ត្រូវធ្វើតាមបញ្ជាយើងគ្រប់យ៉ាង ប្រយ័ត្នយើងបាញ់បំបែកលលាដ៍ក្បាលទាំងពីរនាក់ ខានសប្បាយភ្លើតភ្លើនទៀតហ្នា: !

ថាវីរើបក្បាលពីស្មាប្ដីយ៉ាងរហ័ស ដូចត្រូវនឹងរន្ទះបាញ់ ហើយមុខនាងឡើងសស្លាំងដូចទេសឯកមួយរំពេច នាងប្រុងងាកមករកម្ចាស់សំលេង ៖

-កុំងាកឱ្យសោះមើលតែទៅមុខបានហើយ តែថៅកែត្រូវតែកាន់ចង្កូតតាមសម្រួលទៅ ទើបបានសុខខ្លួន !

ថៅកែមុយលួចវាត់កន្ទុយភ្នែក សម្លឹងកញ្ចក់មួយភ្លែត តែគាត់អាចឃើញតែចុងកាំភ្លើងខ្មៅក្រិប និងមួកជនចំឡែកនេះប៉ុណ្ណោះ ។



-លោកជានរណា ? ថៅកែមុយសួរទាំងញ័រៗ

-គង់តែស្គាល់ទៅថ្ងៃមុខ ប៉ុន្តែឥឡូវត្រូវបញ្ជាឡានឱ្យត្រង់ទៅមុខហើយចាំស្ដាប់បញ្ជាយើងគ្រប់យ៉ាង ! ឯអ្នកស្រីសុំប្រគល់កាបូបនោះមកឱ្យខ្ញុំភ្លាមមក !

ថាវីរេរាក្នុងចិត្តមួយសន្ទុះ ទើបចាប់កាបូបលើភ្លៅប្រុងបើកយកកាំភ្លើង តែជនចំឡែកវៃណាស់ គេរុញរបស់គេភ្ជង់កញ្ចឹងកនាងជាប់ហើយសន្ធាប់ដោយសម្លេងធ្ងន់ៗថា ៖

-មិនបាច់ប្រើល្បិចជាមួយយើងទេអ្នកស្រី ! ល្បិចអស់នេះយើងធ្លាប់ស្គាល់រួចមកហើយ សុំប្រគល់ឱ្យយើងតាមស្រួលមក !

ថាវីមិនទាន់ទាំងកម្រើកខ្លួនផង ស្រាប់តែដៃជនចំឡែកលូកមកកញ្ឆក់យកបានទៅស្រេចហើយ ទើបនាងផ្ដង់ស្មារតីសួរថ្មមៗ ៖

-លោកគិតនាំពួកយើងទៅណាហ្នឹង ?

-យើងធ្វើការមានគោលដៅ មានច្បាប់សំរាប់បញ្ជាពីលើ យើងមិនមែនប្រព្រឹត្តដោយកម្លាំងចិត្ត ឃោរឃៅលោភលន់ដូចពួកអ្នកស្រីទេ !

រថយន្តលូនឆ្លងផុតពីមុខស្នងការដ្ឋាន ហើយក៏បង្ហួសទៅឈប់ពីមុខភូមិគ្រឹះតូចមួយ ងងឹតស្ងួនស្ងាត់សុងពុំមានពន្លឺអ្វីជះមកក្រៅបន្តិចសោះ ហើយទ្វាររបងក៏ចំហស្រាប់ បីដូចជាមានមនុស្សបើកចាំជាស្រេច ។

-បត់ចូលទៅក្នុងភូមិនោះទៅ ហើយពន្លត់ហ្វារភ្លាម !

ហ្វាររថយន្តក៏រលត់ភ្លឹប រថយន្តក៏បត់ចូលទៅឈប់ពីមុខទ្វារផ្ទះដ៏

ទំនើបនោះភ្វាម បន្ទាប់មកទ្វារខាងក្រោយក៏របើកខ្ទាំងឡើងយ៉ាងរហ័ស ហើយមនុស្សម្នាក់លោតភ្លែតចេញទៅក្រៅ ដោយគ្រងសំលៀកបំពាក់សម្បុរគគី និងពាក់ម្នូកទម្នាក់បាំងមុខជិត ដើរមកបើកទ្វារឱ្យថៅកែនិងប្រពន្ធចេញ ដោយពោះសំដីគម្រាមថា ÷

-នៅក្នុងភូមិគ្រឹះនេះ មានគ្រោះថ្នាក់គ្រប់ជំហាន ពុំមានប្រាប់ឱ្យដឹងមុនទេ ត្រូវតែអ្នកទាំងពីរប្រយ័ត្នខ្លួនបន្តិច ហើយបើមិនស្តាប់យើងទេ ដល់មានគ្រោះថ្នាក់កើតឡើងដោយចៃដន្យ កុំទម្លាក់កំហុសមកលើយើងឱ្យសោះហ្នា !

ជនចំឡែកបញ្ជាឱ្យថៅកែនិងប្រពន្ធដើរមុខ មកដល់មាត់ទ្វារដែលធ្វើឡើងអំពីកញ្ចក់ ជននោះក៏លូកដៃរុញទ្វារបើកឱ្យអ្នកទាំងពីរចូលទៅក្នុងបន្ទប់ងងឹត ព្រមទាំងរុញកៅអីមកឱ្យអ្នកទាំងពីរអង្គុយ ដោយពុំមានបើកភ្លើងឱ្យមានពន្លឺដល់បន្តិចឡើយ ។ ជនចំឡែកព្រមានទៀត ÷

-នៅក្នុងបន្ទប់ងងឹតនេះ រិតតែមានគ្រោះថ្នាក់ច្រើនរាប់មិនអស់ទៀត ព្រោះជាគ្រោះថ្នាក់កើតឡើងគ្មានឱ្យដំណឹងមុន !

-ម៉េចក៏លោកមិនបើកភ្លើងឱ្យភ្លឺឡើងផងទៅ ! សម្លេងថាវីពោលខ្សាវៗក្នុងទីងងឹត ។

-អង្គុយឱ្យតែស្ងៀមសិន កិច្ចបញ្ហាផ្សេងៗនៅលើខ្ញុំទាំងអស់ ! សម្លេងជនអាថ៌កំបាំងតបពីជ្រុងម្ខាងមកវិញ ។

ខណៈនោះពន្លឺភ្លើងមួយដុំ ក៏ជះឆ្វាចឡើងមកចំមុខថៅកែនិងភរិយាឡើងស្រវាំងភ្នែក រកតែមើលអ្វីក៏មិនច្បាស់ ។ ថៅកែមុយប្រឹង



បើកភ្នែកសង្កេតទៅស្បែរភ្លើងនោះ ឃើញមានស្រមោលមនុស្សម្នាក់អង្គុយនៅពីក្រោយការិយាល័យ ជក់បារីបង្ហុយផ្សែងទ្រលោម ។ ថាវីនឹកក្តៅចិត្តឥតឧបមា ចំពោះគ្រោះថ្នាក់កើតឡើងដោយចៃដន្យយ៉ាងនេះ ហើយគួរឱ្យបារម្ភណាស់ទៀត គឺមិនដឹងថាតើបុរសអង្គុយនៅពីមុខនេះជានរណា ? ចេញពីប្រភពណាមក ? ឬមួយជាលោកស្នងការទេដឹង ? នាងគិតមិនទាន់យល់ផង សម្លេងបុរសនោះសួរមកដោយធ្ងន់ ៗយ៉ាងច្បាស់ឥតមានញ័រឬតតិបតតុប ÷

-អ្នកស្រីថាវី ! ខ្ញុំដឹងថាឆ្នាំនេះ អ្នកស្រីរកស៊ីបានធូរច្រើនណាស់ ដោយមានថៅកែធំនៅភ្នំពេញ និងនៅហុងកុងជួយឃិតយោងគាំទ្រយ៉ាងអស់សមត្ថភាព ។ តើអ្នកស្រីអាចប្រាប់ឈ្មោះថៅកែធំនៅភ្នំពេញនោះ ដល់ខ្ញុំផងបានទេ ?

ថាវីឈ្ងោកមុខចុះ ដោយមិនអាចប្រឹងសម្លឹងរន្ទះភ្លើងបញ្ចាំងនោះបានយូរទៀត ហើយសួរបញ្ច្រាសមកវិញ ÷

-លោកជានរណា ? ហើយមានមុខការជាអ្វីដែរ ទើបបានមកដេញដោលរបររកស៊ីផ្ទាល់ខ្លួនអីចឹង ? បើលោកស្គាល់ឈ្មោះខ្ញុំច្បាស់ក៏លោកអាចស្គាល់មុខរបរជីវៈខ្ញុំដែរ.........

ថៅកែមុយងើបក្បាលបន្តិច លើកដៃបាំងភ្នែក ÷

-ខ្ញុំពីរនាក់ប្តីប្រពន្ធ ជាថៅកែបារកូឡាប-ស ពុំមានមុខរបរអ្វីហួសពីនោះទៀតទេ ?

-ហាំ ៗ ! ថៅកែគ្មានអ្វីក្រៅពីនោះទេ ! ប៉ុន្តែមួយយប់ៗ ថៅកែនិងប្រពន្ធមិនដែលឃើញអើតក្បាល ទៅនៅក្នុងបារនោះមួយម៉ោង